ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសបារាំង

# សេចក្តីជូនដំណឹង

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសបារាំង សូមជម្រាបជូនប្រជាពលរដ្ឋខ្មែរ និងបរទេស មេត្តាជ្រាបថា៖ ក្រសួងមហាផ្ទៃ នឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកសលាកបត្រចូលកម្ពុជា (Cambodia e-Arrival Card) នៅតាមអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា មុនពេលមកដល់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកដំណើរក្នុងការបំពេញបែបបទអន្តោប្រវេសន៍ បែបបទទិដ្ឋាការចូល បែបបទគយ និងបែបបទសុខភាព ក្នុងទម្រង់តែមួយ ដោយកំណត់តំណភ្ជាប់ចូលទៅកាន់គេហទំព័រ https://arrival.gov.kh តាមកម្មវិធី Cambodia e-Arriva (CeA) ដែលមាននៅក្នុង App Store និង Play Store នៅលើទូរស័ព្ទដៃ ឬឧបករណ៍អេឡិចត្រូនិកផ្សេងទៀត ដែលនឹងចាប់ផ្តើមអនុវត្តសាកល្បងចាប់ពីថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤។

ក្នុងដំណាក់កាលអនុវត្តសាកល្បងនេះ អ្នកដំណើរអាចមានជម្រើសក្នុងការបំពេញព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិកសលាកបត្រចូលកម្ពុជាមុនពេលមកដល់ (Cambodia e-Arrival Card) ឬតាមទម្រង់ជាក្រដាសក៏បាន។

ប្រព័ន្ធអេឡិចត្រូនិកសលាកបត្រចូលកម្ពុជាមុនពេលមកដល់ (Cambodia e-Arrival Card) នេះ នឹងចាប់ផ្តើមដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤។

អ្នកធ្វើដំណើរទាំងអស់ត្រូវដាក់សុំ Cambodia e-Arrival Card មុនពេលអ្នកមកដល់ព្រះរាជាណាចក្រកម្ពុជា។

ប៉ារីសថ្ងៃទី២៧ ខែកម្ភៈ ឆ្នាំ២០២៤

4, rue Adolphe Yvon
75116 – PARIS (France)
Tel. : (33) 01 45 03 47 20
Fax : (33) 01 45 03 47 40